GOLDEN TREE



លេខ: GTPR-2403-001

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ភាពមិនច្បាស់លាស់ជាសារវន្តលើនិរន្តភាពនៃរបាយការណ៍ហិរញ្ញវត្ថុត្រីមាសទី៤ឆ្នាំ២០២៣

**ក្រុមហ៊ុន ហ្គោលដេន ទ្រី** (“**ក្រុមហ៊ុន**”) ដែលជាក្រុមហ៊ុនបោះផ្សាយមូលបត្របំណុលបៃតងដំបូងគេនៅ កម្ពុជា និង បានចុះបញ្ជីលើទីផ្សារ មូលបត្រកម្ពុជា (ផមក) កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៣ មានកិត្តិយសសូមជម្រាបជូនវិនិយោគិន និងសាធារណជនមេត្តាជ្រាបថា៖

ក្រុមហ៊ុនសូមលើកឡើងអំពីការបង្ហាញរបស់សវនករ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុក្នុងគ្រាដែលបានពិនិត្យឡើងវិញនៃត្រីមាសទី ៤ ឆ្នាំ ២០២៣ ទាក់ទងនឹងស្ថានភាពចំពោះការមិនអាចកំណត់ភាពសមស្របនៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយផ្អែកលើមូលដ្ឋាននៃនិរន្តរភាព។ ក្រុមហ៊ុនបានយល់ពីភាពចាំបាច់ក្នុងការដោះស្រាយបញ្ហានេះ ហើយក្រុមហ៊ុនបានកំពុងចាត់វិធានការយ៉ាងសកម្ម ដើម្បីដោះស្រាយស្ថានភាពខាងលើ។

បន្ទាប់ពីបានធ្វើកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយភាគហ៊ុនិកតាំងពីឆ្នាំ២០២៣ ក្រុមហ៊ុនបានដាក់ស្នើ ផែនការមួយដែលមានភាពជាក់លាក់និង គ្រប់ជ្រុងជ្រោយ ដើម្បីដោះស្រាយបញ្ហាដែលកំពុងជួបប្រទះ។ ផែនការដែលបានស្នើឡើងនេះ ជាយុទ្ធសាស្ត្រដែលមានការអនុវត្តជាដំណាក់កាលក្នុងគោលបំណងពង្រឹងស្ថេរភាពហិរញ្ញវត្ថុ និងដើម្បីធានាបាននូវនិរន្តរភាពយូរអង្វែងរបស់ក្រុមហ៊ុន។

ធាតុចូលសំខាន់មួយនៃផែនការដែលបានស្នើឡើង គឺការបង្កើនដើមទុន។ ក្រុមហ៊ុនជឿជាក់ថាការបង្កើនដើមទុន នឹងពង្រឹងស្ថានភាពហិរញ្ញវត្ថុ ព្រមទាំងផ្តល់នូវធនធានចាំបាច់ដើម្បីជម្នះបញ្ហាប្រឈមនាពេលបច្ចុប្បន្ន។ យន្តការនេះស្របតាមស្មារតី របស់ក្រុមហ៊ុនក្នុងការធានាឱ្យបាននូវផលប្រយោជន៍របស់វិនិយោគិន និងធានាឱ្យក្រុមហ៊ុន មានការរីកចម្រើន និងទទួលបាននូវភាពជោគជ័យជាបន្តបន្ទាប់ ។

ភាគហ៊ុនិក បានអនុម័តជាគោលការណ៍ដើម្បីបង្កើនដើមទុនក្នុងអំឡុងពេលកិច្ចប្រជុំភាគហ៊ុនិកនៅថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ២០២៣។ ក៏ប៉ុន្តែគិតត្រឹមកាលបរិច្ឆេទចេញរបាយការណ៍នេះ ការដំឡើងដើមទុននេះមិនទាន់ត្រូវបានបញ្ចប់នៅឡើយ។ ក្រុមហ៊ុន បាននឹងកំពុងបន្តធ្វើការជាមួយភាគហ៊ុនិកហើយមានសុទិដ្ឋិនិយមថាបញ្ហានេះនឹងត្រូវបានដោះស្រាយនៅពេលអនាគតដ៏ខ្លីខាងមុខ។

ក្រុមហ៊ុនតែងតែប្រកាន់ខ្ជាប់នូវតម្លាភាពព័ត៌មានជូនវិនិយោគិន។ ក្រុមហ៊ុននឹងបន្តផ្តល់នូវព័ត៌មានចាំបាច់ជាបន្តបន្ទាប់ជូនចំពោះវិនិយោគិន អំពីវឌ្ឍនៈភាពនៃការអភិវឌ្ឍផែនការខាងលើ។ ក្រុមហ៊ុនសូមថ្លែងអំណរគុណចំពោះការគាំទ្រ និងការជឿជាក់របស់វិនិយោគិនមកលើក្រុមហ៊ុនក្នុងការដោះស្រាយ និងជម្នះបាននូវឧបសគ្គនាពេលបច្ចុប្បន្នឱ្យបានជោគជ័យ។

ម្ចាស់មូលបត្របំណុលវិនិយោគិននិងសាធារណជនគួរពិនិត្យមើលព័ត៌មានបន្ថែមដែលបានផ្សព្វផ្សាយក្នុងរបាយការណ៍ក្រុមហ៊ុនសម្រាប់ត្រីមាសទី៤ឆ្នាំ២០២៣៖

១.របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រានៃត្រីមាសទី៤ ដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធក្នុងរបាយការណ៍ត្រីមាសទី៤ របស់ក្រុមហ៊ុន

- របាយការណ៍សវនករ
- កំណត់សម្គាល់ទី៣.២

២. របាយការណ៍ត្រីមាសទី៤របស់ក្រុមហ៊ុន

- ផ្នែកទី១ ចំណុច ឃ៖ ចំណាប់អារម្មណ៍របស់សវនករលើភាពមិនច្បាស់លាស់ជាសារវន្តលើនិរន្តរភាព

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនមេត្តាទទួលជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃ ពុធ ១១ រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ត្រូវនឹង ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២៤

**ក្រុមហ៊ុន ហ្គោលដេន ទ្រី**